00847579

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 09 / 2012
ម៉ោង (Time/Heure) : 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E138/1/10/1/2/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

N.O : 10179/ស.ម. អវ.ត.ក

**ជម្រាបជូន:** **លោក ម៉ៅ សុភារម្យ** ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១២
ប្រធានមន្ទីរឃុំឃាំងបណ្តោះអាសន្ននៃ
អ.វ.ត.ក

**ពី:** **ឯកឧត្តម ក្រោញ់ តូនី** ប្រធានការិយាល័យរដ្ឋបាលស្តីទី
**លោក Knut Rosandhaug** អនុប្រធានការិយាល័យរដ្ឋបាល

16.09.2012

**កម្មវត្ថុ:** អំពីការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំងបណ្តោះអាសន្ន នៃ អ.វ.ត.ក

**យោង:**
- លិខិតរបស់ប្រធានមន្ទីរឃុំឃាំងបណ្តោះអាសន្នស្តីពីការដោះលែង អៀង ធីរិទ្ធ ពីមន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់អ.វ.ត.ក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២
- ដីកាបង្គាប់របស់សហព្រះរាជអាជ្ញាចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ ផ្ញើរជូនប្រធានមន្ទីរឃុំឃាំងបណ្តោះអាសន្ន អ.វ.ត.ក បង្គាប់ឲ្យដោះលែង អៀង ធីរិទ្ធ ជាបន្ទាន់
- ដីកាសម្រេចរបស់ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក លើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២

យើងធ្វើការកត់សម្គាល់ សេចក្តីសម្រេចចេញដោយអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ បញ្ជាឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ និង ដីកាពីសហព្រះរាជអាជ្ញានៅកាលបរិច្ឆេទដូចគ្នាបញ្ជូនទៅប្រធានមន្ទីរឃុំឃាំងបណ្តោះអាសន្ននៃ អ.វ.ត.ក ឲ្យដោះលែង អៀង ធីរិទ្ធ ជាបន្ទាន់។

00847580

យើងធ្វើការកត់សម្គាល់ផងដែរនូវ សេចក្តីសម្រេចចេញដោយសាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ តែងតាំង អៀង វិជីដា ដែលជាកូនស្រីរបស់ អៀង ធីរិទ្ធ ជាអាណាព្យាបាលទូទៅរបស់ អៀង ធីរិទ្ធ។

យោងតាមលិខិតរបស់លោកចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ និងកថាខ័ណ្ឌ២ នៃវិធាន២៥ នៃវិធានសម្រាប់គ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះ ឬ ប្តឹងឧទ្ធរណ៏ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក សូមបញ្ជាក់ថា: ក្នុងនាមលោកជាប្រធានមន្ទីរឃុំឃាំងបណ្តោះអាសន្ន នៃ អ.វ.ត.ក តំណាងឲ្យអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា លោកត្រូវដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ អនុលោមតាមដីកាសម្រេចរបស់ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ និងអនុលោមតាមដីកាបង្គាប់របស់សហព្រះរាជអាជ្ញា ឲ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ដែលត្រូវបានតែងតាំងដោយសាលាដំបូងរាជធានីភ្នំពេញ។